# សេចក្តីជូនដំណឹងចំពោះអ្នកទទួលជំនួយពីកម្មវិធី CALFRESH
# សំខាន់ – សូមអាន

ចាប់ពីថ្ងៃទី 1ខែកក្កដា ឆ្នាំ 2014, ច្បាប់រដ្ឋមួយចំនួនបានត្រូវកែប្រែ ។ ក្រុមគ្រួសារខ្លះៗប្រហែលអាចមានលទ្ធភាពទទួលជំនួយរដ្ឋសំរាប់ជួយបង់ថ្លៃទឹក-ភ្លើង (SUAS) ។ ជំនួយនេះត្រូវបានផ្តល់ឲ្យម្តងក្នុងអំឡុងពេលធ្វើការបញ្ជាក់ការទទួលជំនួយ តែប៉ុណ្ណោះ ។ ជំនួយនេះសំរាប់ក្រុមគ្រួសារដែលទទួលជំនួយពីកម្មវិធី CalFresh មួយចំនួន តែប៉ុណ្ណោះ ។ ក្រុមគ្រួសារដែលនឹងទទួលជំនួយសំរាប់ទឹក-ភ្លើងនេះគឺក្រុមគ្រួសារដែល ៖

- មិនមានវិក្កយបត្រដោយឡែកពីវិក្កយបត្រជួលផ្ទះ/និក្ខេប,
- មិនទាន់បានទទួលជំនួយជាអតិបរមាពីកម្មវិធី CalFresh សំរាប់ទំហំនៃចំនួនសមាជិកក្រុមគ្រួសាររបស់គេ,
- មិនទទួលបាននូវការកាត់បន្ថយកំរិតអតិបរមាសំរាប់ជម្រក; ឬ,
- មិនទាន់ទទួលបានប្រាក់កំណើននៃជំនួយដោយមកពីការកាត់បន្ថយសំរាប់ជម្រកនៃការគ្មានផ្ទះសម្បែង ។

ក្រុមគ្រួសាររបស់អ្នកមានលក្ខណសម្បត្តិទទួលជំនួយ SUAS ។ ប្រាក់បង់ឲ្យប្រចាំឆ្នាំចំនួន $20.01 នឹងត្រូវដាក់នៅក្នុងគណនីយនៃការបញ្ជូនប្រាក់តាមអេឡិចត្រូនិច (EBT) ។ ប្រាក់ជំនួយសំរាប់ SUAS ចំនួន ($20.01) អាចប្រើសំរាប់ទិញចំណីអាហារ ឬជាប្រាក់ ។ បើសិនជា បច្ចុប្បន្ននេះអ្នកមិនមានគណនីយប្រាក់ EBT នោះអ្នកត្រូវតែបើកគណនីយ មួយ ។ ប្រាក់នេះអនុញ្ញាតឲ្យខោនធីប្រើប្រាក់កាត់បន្ថយសំរាប់ទឹក-ភ្លើងខ្ពស់បំផុត (ប្រាក់វិភាជន៍ទឹក-ភ្លើងតាមបទដ្ឋាន – SUA) សំរាប់ជំនួយចំណីអាហារ ។ នៅពេលធ្វើការបញ្ជាក់ជំនួយរបស់អ្នកលើកក្រោយ បើសិនជាក្រុមគ្រួសារអ្នកមិនមានលក្ខណសម្បត្តិទៀត ទេ (យោងតាមព័ត៌មានខាងលើ) នោះអ្នកនឹងមិនទទួលប្រាក់ $20.01 ពីកម្មវិធី SUAS ទេ ។ បើសិនជាអ្នកចង់ដឹងច្រើនថែមទៀត សូមទូរស័ព្ទមកអ្នកធ្វើការរបស់អ្នក ។

## សូមធ្វើតាមតម្រុយណែនាំខាងក្រោមនេះ ដើម្បីបង្កើននូវការសន្សំប្រាំមពលអគ្គិសនីរបស់អ្នកនៅតាមផ្ទះ ៖

- យកបន្ទះការពារអាកាសធាតុបិទជុំវិញបង្អួច និងទ្វារ
- យកបន្ទះអ៊ិនសុឡេស្យុង ឬភួយអ៊ិនសុឡេស្យុងរុំជុំវិញធុងទឹកក្តៅ
- មួលទែរម៉ូស្តាតធុងទឹកក្តៅដាក់កំរិត 140 ដឺក្រេ ឬ " ធម្មតា" បើសិនជាអ្នកមានម៉ាស៊ីនលាងចាន ។ បើពុំនោះទេ មួលវាដាក់កំរិត 120 ដឺក្រេ ឬ "ទាប" ។ ពិនិត្យមើលការណែនាំក្នុងម៉ាស៊ីនលាងចានរបស់អ្នក ថាតើអ្នកអាចប្រើទឹកមានកំរិត 120 ដឺក្រេ ដែរឬទេ ។
- ប្រើអំពូលភ្លើង compact fluorescent ជំនួស អំពូល incandescent – អំពូលនេះ ប្រើប៉ាមពលអគ្គិសនី 75% តិចជាង ហើយប្រើបានយូរ10 ដងទៀតផង
- សំអាត ឬផ្លាស់តម្រងចង្ក្រានកំដៅ និងម៉ាស៊ីនត្រជាក់ឲ្យបានទៀងទាត់
- មួលទែរម៉ូស្តាតចង្ក្រានកំដៅដាក់កំរិត 68 ដឺក្រេ ឬទាប ហើយទែរម៉ូស្តាតម៉ាស៊ីនត្រជាក់ត្រឹមកំរិត 78 ដឺក្រេ ឬខ្ពស់ជាង, ឬតាមកំរិតសុខភាពអនុញ្ញាត . 3 ភាគរយ ទៅ 5 ភាគរយ ប៉ាមពល ត្រូវបានប្រើថែមទៀតសំរាប់មួយដឺក្រេៗ ដែលចង្ក្រានកំដៅបានដាក់ត្រង់កំរិត 68 ដឺក្រេ ហើយមួយដឺក្រេៗសំរាប់ម៉ាស៊ីនត្រជាក់ដាក់ត្រង់កំរិតក្រោម 78 ដឺក្រេ
- ជួសជុលបំពង់ទឹកណាដែលធ្លាយ លេចទឹក និងក្បាលម៉ាស៊ីនទឹកដែលមានទឹកស្រក់
- បិទវាំងននបាំងថ្ងៃលើបង្អួចរបស់អ្នកដែលបែរទៅ ទឹសខាងត្បូង/ ឬទិសខាងលិច ដើម្បីទប់ពន្លឺថ្ងៃឲ្យនៅក្នុងផ្ទះ ។ នៅរដូវរងារ បើកវាំងននបាំងថ្ងៃចេញនៅពេលណាមានពន្លឺថ្ងៃ ដើម្បីជួយឲ្យមានកំដៅក្នុងបន្ទប់នានា ។
- រំលាយអាហារកកទាំងឡាយពីក្នុងទូទឹកកកមុនពេលចំអិន
- ប្រើភ្លើងបំភ្លឺចង្ក្រានសំរាប់ពិនិត្យមើលអាហារកំពុងចំអិន ពេលដាំស្ល ឬដុតចំអិនអាហារ ជាជាងបើកទ្វារចង្ក្រាន
- មួលកំរិតសីតុណ្ហភាពក្នុងទូទឹកកកដាក់កំរិត 36° ទៅ 39° F និងកន្លែងកកក្នុងកំតិត 0° ដឺក្រេទី 5° F
- បិទភ្លើងបំភ្លឺ, ទូរទស្សន៍ និងប្រដាប់ប្រើប្រាស់ ផ្សេងៗ ពេលណាមិនត្រូវបានប្រើប្រាស់
- ដកខ្សែភ្លើងចេញពីកុំព្យូទ័រ ឬគ្រឿងប្រដាប់ប្រើប្រាស់នានាដែលប្រហែលនៅតែប្រតិបត្តិទោះជាបិទរួចហើយក៏ដោយ